ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍
# ភូមិកោះព្រះ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

សហគមន៍នេសាទ ៖ ភូមិកោះព្រះ
ភូមិ ៖ កោះព្រះ
ឃុំ ៖ កោះព្រះ
ស្រុក ៖ សៀមបូក
ខេត្ត ៖ ស្ទឹងត្រែង

ខែ កុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ភូមិកោះព្រះ សម្រាប់រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះព្រះ |
| ភូមិ | ៖ | កោះព្រះ |
| ឃុំ | ៖ | កោះព្រះ |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែ កុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះព្រះ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះព្រះ |
| ភូមិ | ៖ | កោះព្រះ |
| ឃុំ | ៖ | កោះព្រះ |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែ កុម្ភៈ ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ..... ៣
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ៤
ក. ប្រជាពលរដ្ឋ ..... ៤
ខ. មុខរបរ ..... ៤
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ..... ៥
ក. ទីតាំង ..... ៥
ខ.ដែននេសាទ ..... ៥
គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..... ៧
ឃ.ធនធានជលផល ..... ៨
៤. ការធ្វើនេសាទ ..... ៨
ក. អ្នកនេសាទ ..... ៨
ខ. ឧបករណ៍នេសាទ ..... ៨
គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..... ១០
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ១០
ក. ទស្សនៈវិស័យ ..... ១០
ខ. គោលដៅបំណងរួម ..... ១០
គ. គោលបំណងជាក់លាក់ ..... ១០
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ១០
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ..... ១០
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ..... ១២
ឃ.៣. ការងារគ្រប់គ្រង ..... ១៦
ង. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ១៩
ច. យុទ្ធសាស្ត្រ ..... ១៨
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា២០១៩- មិថុនា ២០២២) ..... ២១
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា២០១៩- មិថុនា ២០២២) ..... ២៨

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិកោះព្រះ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០០ ហើយបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១ សម្រាប់រយៈពេលបីឆ្នាំ គឺចាប់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ សម្រាប់រយៈពេលបីឆ្នាំ ចាប់ពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៩ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ និងត្រូវបានទទួលស្គាល់ដោយប្រកាសចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សហគមន៍នេសាទនេះមានទីតាំងស្ថិតនៅក្នុងភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន ៥១៣នាក់ ស្រីចំនួន ២៥១នាក់ ស្មើនឹង ២១៦គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០២នាក់ និងមានក្រុមល្បាតចំនួន ០៤នាក់។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទនេះ បានអនុវត្តសកម្មភាពសំខាន់ៗដូចជា ការរៀបចំរចនាសម្ព័ន្ធ និងបញ្ជីឈ្មោះរបស់គណៈកម្មការសហគមន៍នេសាទ ការរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ការចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ ការរៀបចំ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទ ការរៀបចំក្រុមល្បាត ការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ការចុះល្បាតជាប្រចាំដោយសហការជាមួយសមត្ថកិច្ចជលផល អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍ភូមិកោះព្រះ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនេះ នៅជួបប្រទះសកម្មភាពប្រឈមដែលកើតមានក្នុងតំបន់ដូចជាការកាប់បំផ្លាញព្រៃលិចទឹក ការប្រើឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់គ្រឿងផ្ទុះ ឧបករណ៍ឆក់ មងក្រឡាធំ និងសារធាតុពុល)ជាដើម។ ម្យ៉ាងវិញទៀត សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង ៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមានការបាត់បង់ប្រភេទត្រីធំ និងតូចមួយចំនួន និងបាត់បង់ទីជម្រកត្រី ការធ្វើនេសាទខុសច្បាប់កើនឡើង នេសាទនៅក្នុងកន្លែងអន្លង់អភិរក្ស ផលត្រីថយចុះតម្រូវការត្រីកើនឡើង

- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋមិនសូវមានចំណេះដឹង និងបច្ចេកទេសធ្វើស្រែចំការ ខ្វះកម្លាំងអូសទាញ ខ្វះមុខរបរចិញ្ចឹមជីវិត ខ្វះការចូលរួមពីប្រជាពលរដ្ឋ ខ្វះដើមទុនពង្រីកមុខរបរ គ្មានមណ្ឌលសុខភាព មិនមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងមិនមានអនុវិទ្យាល័យ

- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន ខ្វះការយល់ដឹងពីច្បាប់ជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ហើយអាជ្ញាធរមិនសូវសហការ សមត្ថភាពទប់ស្កាត់បទល្មើសរបស់គណៈកម្មការនៅមានកម្រិត មានការឃុបឃិតរវាងជនល្មើសជាមួយសមត្ថកិច្ច ជនល្មើសមិនរាងចាល ជនល្មើសមិនខ្លាចសហគមន៍ ខ្វះការលើកទឹកចិត្ត ខ្វះថវិកាល្បាត និង

សម្ភារល្បាត សហគមន៍ខ្វះថវិកា និងមធ្យោបាយ បទល្មើសនេសាទកើនឡើង សមាជិកសហគមន៍យល់ថាការងារគ្រប់គ្រងសហគមន៍នេសាទជាតួនាទីរបស់គណៈកម្មការ ហើយម្យ៉ាងទៀតជាតួនាទីរបស់គណៈកម្មាការជាបុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងដំបន់នៃសហគមន៍សរុប ១.៤៨៤នាក់ ក្នុងនោះស្រី ៧៧០នាក់ ស្មើនឹង៣៨២គ្រួសារ។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន ១០០%។

ស្ថានភាពប្រជាពលរដ្ឋនៃភូមិកោះព្រះ មានដូចខាងក្រោម ៖

- ចំនួនស្ត្រីជាមេគ្រួសារក្នុងសហគមន៍នេសាទមាន២៥នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៣៤ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស១៧ នាក់ ស្រី០៨នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៤០ នាក់ ស្រី៣៥នាក់
- កម្រិតសិក្សាអប់រំរួមមាន ថ្នាក់បឋមសិក្សាចំនួនសរុប ១៥៨នាក់ ស្រី៧៧នាក់ អនុវិទ្យាល័យចំនួនសរុប ៥១នាក់ ស្រី២២នាក់ វិទ្យាល័យចំនួនសរុប១០នាក់ ស្រី ០៦នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងភូមិនៃសហគមន៍រួមមាន ៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន៣៧២ គ្រួសារ ត្រូវនឹង៩៩%
- ធ្វើស្រែចំនួន៧៩គ្រួសារ ដែលមានទំហំដីសរុបចំនួន៥៨០ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន៥៥គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមានទំហំ០៦x០៨ម៉ែត្រ)
- ជាងផ្ទះចំនួន ០១ គ្រួសារ
- ធ្វើចំការចំនួន ១០០គ្រួសារ
- លក់ដូរជាអាជីព ០២គ្រួសារ
- ប្រមូលទិញផលនេសាទ ០៤គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ៤០គ្រួសារ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប ៣០០គ្រួសារ រួមមានដូចជាផ្អក ប្រហុក ត្រីប្រៃជាដើម។ ក្នុងមួយគ្រួសារអាចផលិតបានពី២០គីឡូក្រាម ទៅ២៥គីឡូក្រាម/ឆ្នាំ
- ជាងកាត់ដេរ០២ គ្រួសារ
- ពេទ្យសត្វ០១ នាក់

- សិប្បកម្មគ្រឿងសង្ហារឹម ០១គ្រួសារ
- មន្ត្រីរាជការ ២៨នាក់ ស្រី១០នាក់
- ចំណាកស្រុក ០៩នាក់ ស្រី០២នាក់។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិកោះព្រះ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិកោះព្រះ មានទំហំ ១.៣៥១ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u> ៖

- ខាងជើងទល់នឹងកោះទ្រាំង ឃុំកោះស្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងត្បូងទល់នឹងកោះតាណាំ និងកោះជ្រឹម ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងកើតទល់នឹងកាំងក្របី ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹងកន្លែងនេសាទសហគមន៍សៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិកោះព្រះ មានវិសាលភាពនៅក្នុងទន្លេមេគង្គ មានអូរចំនួន១៧ ត្រពាំងចំនួន១៥ កោះចំនួន០២ កាំងចំនួន១១ និងអន្លង់ចំនួន០១។

ខ.១ អូរ

| ឈ្មោះអូរ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| អូរល្វា(មានដើមល្វាក្បែរ) | ៨០០ | ខែ ០៨ - ខែ ១០ |
| អូរតាជឿង | ១.០០០ | ខែ ០៨ - ខែ ១០ |
| អូរតាវ៉េន | ៥០០ | ខែ ០៨ - ខែ ១០ |
| អូរតាឈន | ១០០ | ខែ ០៨ - ខែ ១០ |
| អូរយាយកង | ១.៥០០ | ខែ ០៨ - ខែ ១០ |
| អូរតាព្រុញ | ១.០០០ | ខែ ០៨ - ខែ ១០ |
| អូរតាធន | ១.០០០ | ខែ ០៨ - ខែ ១០ |
| អូរតាហ៊ឹម | ១.០០០ | ខែ ០៨ - ខែ ១០ |
| អូរញ្ញើ | ៤.០០០ | ខែ ០៨ - ខែ ១០ |
| អូរត្រពាំងគ្រោះ | ៥០០ | ខែ ០៨ - ខែ ១០ |
| អូរស្វាយ | ៥០០ | ខែ ០៨ - ខែ ១០ |
| អូរស្តី | ៥០០ | ខែ ០៨ - ខែ ១០ |

| | | |
|---|---|---|
| អូរក្រសាំង | ៨០០ | ខែ ០៨ - ខែ ១០ |
| អូរចំប៉ា | ១០០ | ខែ ០៨ - ខែ ១០ |
| អូរក្វរ | ២.៥០០ | ខែ ០៨ - ខែ ១០ |
| អូរតាស៊ូ | ៥០០ | ខែ ០៨ - ខែ ១០ |

### ខ.២ ត្រពាំង

| ឈ្មោះត្រពាំង | ទទឹង បណ្តោយ (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ត្រពាំងគ្រោះ | ១០០ × ១០០ | ខែ ០៨ - ខែ ១០ |
| ត្រពាំងឈើជ្រុំ | ២៥ ×២៥ | ពេញមួយឆ្នាំ |
| ត្រពាំងទង្គឹត | ២៥ ×២៥ | ខែ០៧-ខែ១១ |
| ត្រពាំងណាងប៉ែន | ៤០ ×៥០ | ខែ០៧-ខែ១១ |
| ត្រពាំងស្មាច់ | ២៥ ×២៥ | ខែ០៧-ខែ១១ |
| ត្រពាំងក្បាលស្វា | ២៥ ×២៥ | ខែ០៧-ខែ១១ |
| ត្រពាំងវែង | ៥០ ×១០០ | ខែ០៧-ខែ១១ |
| ត្រពាំងពងទឹក | ៣០ ×៣០ | ខែ០៧-ខែ១១ |
| ត្រពាំងបាញ់ខ្លា | ២០ ×២៥ | ខែ០៧-ខែ១១ |
| ត្រពាំងឈូក | ១៥ ×២០ | ខែ០៧-ខែ១១ |
| ត្រពាំងស្វាយ | ២៥ ×៣០ | ខែ០៧-ខែ១១ |
| ត្រពាំងព្រៃ | ៥០ ×៥០ | ខែ០៧-ខែ១១ |
| ត្រពាំងពស់ថ្លាន់ | ២០ ×២៥ | ខែ០៧-ខែ១១ |
| ត្រពាំងមន្លង់ | ២០ ×២០ | ពេញមួយឆ្នាំ |
| ត្រពាំងតាប៉ាង | ១៥ ×១៥ | ខែ០៧-ខែ១១ |

### ខ.៣ កោះ

| ឈ្មោះកោះ | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះព្រាលតូច | ៧០០ x ១៥០០ | ១០៥ ហិកតា |
| កោះកាំងកូនសត្វ | ៥០ x ១០០ | ០.៥ហិកតា |

### ខ.៤ កាំង (ថ្មតូចៗប៉ប្រះទឹកដែលមានដុះស្មៅ)

| ឈ្មោះកាំង | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កាំងក្អែក | ៥០ x ២០០ | ១ |
| កាំងភូមិ | ១០០ x ១០០ | |

| | | |
|---|---|---|
| កាំងតាហ៊ីម | ៥០ x ២០០ | ១ |
| កាំងអូរញ្ញៅ | ៥០ x ២០០ | ១ |
| កាំងអន្លង់វៀន | ៥០ x ២០០ | ១ |
| កាំងអូរក្រសាំង | ៥០ x ១០០ | ០.៥ |
| កាំងអូរក្សរ(កាំងធំ) | ៣០ x ៨០០ | ២.៤ |
| កាំងធុង | ១៥ x ១០០ | ០.១៥ |
| កាំងទទឹងកោះព្រាល | ១៥ x ២០០ | ០.៣ |
| កាំងកំបុត | ២០ x ១៥០ | ០.៣ |
| កាំងព្រីង | ២៥ x ២០០ | ០.៥ |

ខ.៣ អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់សៀមបូក | ២០០ x ៣០០០ | ៦០.០០០ | ៣៥ | ២៥ |

កន្លែងនេសាទសហគមន៍ភូមិកោះព្រះ មានព្រៃលិចទឹកទំហំសរុប០៧ ហិកតា ក្នុងនោះមានប្រភេទព្រៃដើមរាំង ដើមរ៉ៃ ដើមឫស្សី ដើមត្រែង ដើមត្រស់ ដើមល្វា ដើមប៉ាង មានទំហំ ០៤ ហិកតា និងព្រៃលិចទឹកចំរុះទំហំ៣ ហិកតានៅក្នុងកន្លែងនេសាទសហគមន៍ភូមិកោះព្រះ។

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទភូមិកោះព្រះមានអន្លង់អភិរក្សចំនួន១គឺអន្លង់សៀមបូក ដូច្នេះសហគមន៍បានសម្រេចឯកភាពមិនបង្កើតអន្លង់អភិរក្សបន្ថែមទៀតទេ។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់សៀមបូក | ២០០ x ៣០០០ | ៦០.០០០ | ៣៥ | ២៥ |

ឃ.ធនធានជលផល

១.ប្រភេទត្រី៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ាមុខ១ ត្រីប៉ាវ៉ាមុខពីរ ត្រីប៉ាកក ត្រីគ្រុំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីក្របី ត្រីប្រម៉ា ត្រីគ្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទីង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្តោក ត្រីតានេល ត្រីអំបូង ត្រីកញ្ចុះក្តោង ត្រីកំពត ត្រីបបែល ត្រីឫសចេក ត្រីស្លឹកចេក ត្រីចង្វា ត្រីថ្ម ត្រីដំរី ត្រីកំផ្លៀញ ត្រីផ្ទក់ ត្រីផ្កាគ ត្រីអណ្តាតឆ្កែ ត្រីក្អុក ត្រីឆ្វៀត ត្រីកែ ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីកញ្ចុះប៉ាវ៉ា ត្រីស្លាបមាន់ ។

២.ប្រភេទវារីសត្វ៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ឹង។

៣.ប្រភេទបក្សី៖ ក្អែកទឹក កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ ទាទឹក ក្អែកគោក វំពេ ទុង ស្មោច កញ្ចិច ពពេច សារិកាកែវ សេក លលក ពពូល ចាប ត្រចៀកកាំ រមាសអាច ក្លិត វំពេ ក្រយង រនាល ត្រដក់ ក្រសារ។

៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ដើមរៃ ដើមអណ្តែង ដើមជ្រៃ ដើមត្រែង ដើមល្វាទឹក រាំងទឹក ដើមក្តុល ត្រើងទឹក ដើមអញ្ចែង ផ្កា ត្រស់ អញ្ចេរ សណ្តាន់ទឹក សណ្តាន់គោក ញរទឹក ធ្នង ទន្លា កុល ក្របៅ ល្វាស្តី កាម្ទល់ ស្វាយទឹក ពោធិ៍ជ្រៃក្រឹម។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៩៨គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ២៧០គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ១៥គ្រួសារ។

### ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| លប | គ្រឿង | ៥០គ្រួសារx ២=១០០ គ្រឿង | ៥០ គ្រួសារx ២=១០០ គ្រឿង | | មុខកាត់១ម ប្រវែង២ម | មុខកាត់១ម ប្រវែង២ម | | ខែ៦-១២ |
| ចាន់ | គ្រឿង | ៣០គ្រួ X៥ = ១៥០គ្រឿង | | | មុខកាត់ ០.៤ម កំពស់ ០.៧ម | | | ខែ៦-១២ |
| សំណាញ់ | វង់ | ២វង់ X ១២០= ២៤០ គ្រឿង | ២វង់ X ១០០= ២០០ គ្រឿង | សំរុង ៣.៥មX ៥.៥ម | សំរុង ៣.៥មX ៥.៥ម | | | ពេញ១ឆ្នាំ |
| ជុច | គ្រឿង | ២០គ្រួសារ | | | មុខកាត់០.៥ម ប្រវែង០.៩ម | | | ពេញ១ឆ្នាំ |
| សៃយ៉ឺន | គ្រឿង | ៣០គ្រួសារ | | | មុខកាត់ ០.៨ម ប ២,៥ម | | | ខែ៦-១២ |

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៥០ | ៣៤ | | ២០០-៣០០ | | ២០០-៣០០ | ៥ | ៥ | |
| ទូកអេវជាប់ម៉ាស៊ីនHONDA | ២៣៤ | ៤៥ | ១៥ | ២០០-៣០០ | ២០០-៣០០ | ២០០-៣០០ | ៦.៥ | ៦.៥ | ៦.៥ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ៣ | | | ៣០០-៤០០ | ៣០០-៤០០ | ៣០០-៤០០ | ៨ | | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ១០ | | | ៣០០-៥០០ | | ៣០០-៥០០ | ៩ | | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ៣០ | | | ៣០០-៥០០ | | ៣០០-៥០០ | ១៣ | | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | | ៥ | | | ៣០០-៥០០ | | | ១៨ | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | | ៣ | | | ៣០០-៥០០ | | | ២២ | |
| ទូកចែវ | ៣ | | | | | | | | |

គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង (គីឡូក្រាម) | រដូវវស្សា (គីឡូក្រាម) | សរុបប្រចាំឆ្នាំ (គីឡូក្រាម) |
| ត្រី | ៧១៤,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |

## ៥. ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

ក. ទស្សនៈវិស័យ

សហគមន៍នេសាទភូមិកោះព្រះ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ តម្លាភាព និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលដៅបំណងរួម

- ធ្វើឱ្យជីវភាពប្រជាពលរដ្ឋប្រសើរឡើង
- ការពារ និងអភិរក្សធនធានជលផលដើម្បីប្រើប្រាស់ឲ្យមាននិរន្តភាព
- បង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រង និងអភិបាលកិច្ចរបស់សហគមន៍ភូមិកោះព្រះ។

គ. គោលបំណងជាក់លាក់

- ការពារព្រៃលិចទឹកជាជម្រកត្រី
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ និងដាំក្រូចពោធិសាត់ និងពង្រឹងក្រុមសន្សំប្រាក់
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| ទន្លេមេគង្គ | ពេញមួយឆ្នាំ | សំណាញ់ | សម្រុង ៤-៥ម ក្រឡា២-១០ស.ម | ២វង់/គ្រួសារ | ជាលក្ខណៈគ្រួសារ |
| | | ចាន់ | មុខកាត់០.៤ម/ប្រវែង០.៧ម | ១០គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់ ១ម / ប្រវែង២ម | ៦គ្រឿង/គ្រួសារ | |
| | | ជុច | មុខកាត់ ០.៥-០.៩ម ប្រវែង ០.៧ម | ១២គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់០.៨ម /ប្រវែង២,៥ ម | ១០គ្រឿង/គ្រួសារ | |
| អូរលិចទឹករដូវវស្សា | ខែ០៦ - ខែ១១ | សំណាញ់ | សម្រុង ៤-៥ម ក្រឡា២-១០ស.ម | ២វង់/គ្រួសារ | |
| | | ចាន់ | មុខកាត់០.៤ម/ប្រវែង០.៧ម | ១០គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់ ១ម / ប្រវែង២ម | ៦គ្រឿង/គ្រួសារ | |
| | | ជុច | មុខកាត់ ០.៥-០.៩ម ប្រវែង ០.៧ម | ១២គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់០.៨ម /ប្រវែង២,៥ ម | ១០គ្រឿង/គ្រួសារ | |

ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ / ចំនួន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| តំបន់អភិរក្ស អន្លង់សៀមបូក ០៦ហិកតា | • ផ្ទាំងប៉ាណូសហគមន៍នេសាទ ២ផ្ទាំង<br>• ដាក់ពោងកន្លែងអភិរក្ស ៥ពោង | • ផលិតនិងបោះផ្ទាំងប៉ាណូផែនទី<br>• ទិញ និងបោះពោង ចំនួន៥ពោង | • គណៈកម្មការ<br>• សមាជិកស.ន<br>• មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |
| កន្លែងនេសាទសហគមន៍កោះព្រះ ១.៣៥១ ហិកតា | បង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន ០៦បង្គោល | រៀបចំក្រុមបោះបង្គោល(ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមបោះបង្គោលព្រំប្រទល់តាមនិយាមកា)<br>• ផ្សព្វផ្សាយជាសាធារណៈ<br>• ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល។ | • គណៈកម្មការ<br>• សមាជិកស.ន<br>• មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |

ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ថែរក្សាព្រៃលិចទឹកនៅកោះព្រៀល | ០១ | ដាំដើមរៃ រាំង ត្រស់ ១០.០០០ ដើម | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់ចំនួន ៣០។ | ៧/២០១៩ | ៦/២០២២ | |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការបង្កើតមុខរបរបង្កើនប្រាក់ចំណូល

ផែនការបង្កើតមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខសកម្មភាព | សកម្មភាព | ប្រភេទ | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៥០ គ្រួសារចិញ្ចឹមគោ (ធនាគារគោ) | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមគោ<br>• ចែកពូជគោ<br>• តាមដានត្រួតពិនិត្យ ។ | ពូជគោ | ៥០គ្រ x ០២ ក្បាល | ៧/២០១៩ | ៦/២០២២ |
| ២០ គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសអ្នកទទួល ផល<br>• បណ្ដុះបណ្ដាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្ដល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ។ | ពូជមាន់ក្នុងស្រុក | ២០គ្រ x ១០ ក្បាល | ៧/២០១៩ | ៦/២០២២ |
| ៣០ គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសអ្នកទទួល ផល<br>• បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្ដល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ។ | ពូជជ្រូក | ៣០គ្រ x ០៤ ក្បាល | ៧/២០១៩ | ៦/២០២២ |
| ១០ គ្រួសារចិញ្ចឹមក្របី | • ជ្រើសរើសអ្នកទទួល ផល<br>• បណ្ដុះបណ្ដាល បច្ចេកទេសចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ<br>• ផ្ដល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ។ | ពូជក្នុងស្រុក | ១០គ្រួ x ១ក្ប | ៧/២០១៩ | ៦/២០២២ |
| ២០ គ្រួសារសួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសធ្វើសួនបន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជអនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ។ | បន្លែគ្រប់មុខ | ៣០គ្រ x ៦មុខ | ៧/២០១៩ | ៦/២០២២ |

| | | | | | |
|---|---|---|---|---|---|
| ១០គ្រួសារ បណ្តុះផ្សិតចំបើង | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ។ | ផ្សិតចំបើង | | ៧/២០១៩ | ៦/២០២២ |
| ៥០ គ្រួសារបច្ចេកទេសបណ្តុះពូជស្វាយចន្ទី | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលច្ចេកទេសបណ្តុះពូជចន្ទី<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ។ | ពូជចន្ទី ដែលមានគ្រាប់ធំ | | ៧/២០១៩ | ៦/២០២២ |

ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទ | បរិមាណ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ៥០គ្រួសារ ចិញ្ចឹមត្រីអណ្តែងក្នុងអាងជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• ធ្វើអាងចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដាន | ៥០អាងស៊ីម៉ងត៍ ទំហំ ៣ម×៦ម | ត្រីអណ្តែង | ៥០០០ | ៧/២០១៩ | ៦/២០២២ |
| ០៥គ្រួសារ ចិញ្ចឹមត្រីក្នុងបែរ(ត្រីខ្សា,ត្រីឆ្តោ) | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្នុងបែរ<br>• ធ្វើបែរចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដាន។ | ០៥បែរទំហំ៣ម×៥ម | ត្រីខ្សា | ៥០០ | ៧/២០១៩ | ៦/២០២២ |

ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហ | ៧/២០១៩ | ៦/២០២២ | |

| | | | | |
|---|---|---|---|---|
| ១ ក្រុម | គមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដានត្រួតពិនិត្យ។ | | | |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ធ្វើផ្លូវថ្មីក្រួសក្រហម និងដាក់លូ | ០១ គីឡូម៉ែត្រ | ៧/២០១៩ | ៦/២០២២ |
| ជួសជុលស្ពានឈើក្នុងភូមិ | ០២ កន្លែង | ៧/២០១៩ | ៦/២០២២ |

### ឃ.២.៥. ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ

ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| រៀបចំវគ្គបណ្តុះបណ្តាលអំពីបដិសណ្ឋារកិច្ច | ១វគ្គ/ឆ្នាំ | ខែ កក្កដា ២០១៩ | ខែ កក្កដា ២០២២ | |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពអេកូទេសចរណ៍ | ២ផ្ទាំង | ខែ កក្កដា ២០១៩ | ខែ កក្កដា ២០២២ | |

### ឃ.២.៦.ផែនការទាក់ទងនឹងការរកទីផ្សារ

ផែនការទាក់ទងនឹងការរកទីផ្សារ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ចងក្រងក្រុម និងស្វែងរកឈ្មួញ | • ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសមេដឹកនាំក្រុម<br>• កំណត់ក្រុមឈ្មួញ<br>• តាមដានត្រួតពិនិត្យ។ | ៧/២០១៩ | ៦/២០២២ | |

### ឃ.៣. ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៤ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ៧ អាវ | ៧/២០១៩ | ៦/២០២២ |
| | អាវភ្លៀង | ៧ អាវ | | |

| | | | | |
|---|---|---|---|---|
| | គោមបំភ្លឺពាក់ក្បាល | ៧ គោម | | |
| | វិទ្យុទាក់ទង | ៤ គ្រឿង | | |
| | កែវយឺត | ២ គ្រឿង | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | |
| | អង្រឹង | ៧ អង្រឹង | | |
| | តង់គ្របទូក ៤មគុណ៦ម | ២ តង់ | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | |
| | ស្លាបចក្រ | ៦គ្រឿង | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | |
| | សោរ និងច្រវាក់ចាក់ទូក | ២ ឈុត | | |
| | អាវយឺត | ១៤ អាវយឺត | | |
| ទិញទូកស្ទាច់ម៉ាស៊ីន | | ២ គ្រឿង | ៧/២០១៩ | ៦/២០២២ |
| ប្រេងសម្រាប់ល្បាត | | ១០០លីត្រ/ខែ | ៧/២០១៩ | ៦/២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | | ១ កន្លែង | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ២ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ(តំណាងសហគមន៍នេសាទ) | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ៣ | ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | តាមការអញ្ជើញ | ៧/២០១៩ | ៦/២០២២ |
| ៤ | យុទ្ធនាការផ្សព្វផ្សាយបំផុសការយល់ដឹងអំពីច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | ១ដង/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ៥ | បណ្តុះបណ្តាលគណកម្មការសហគមន៍នេសាទពីច្បាប់ជលផល | ១លើក | ៧/២០១៩ | ៦/២០២២ |
| ៦ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ និងរបាយការណ៍ | ១លើក | ៧/២០១៩ | ៦/២០២២ |
| ៧ | បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | ១លើក | ៧/២០១៩ | ៦/២០២២ |
| ៨ | បណ្តុះបណ្តាលជំនាញសម្របសម្រួល | ១លើក | ៧/២០១៩ | ៦/២០២២ |
| ៩ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ៧/២០១៩ | ៦/២០២២ |
| ១០ | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក | ៧/២០១៩ | ៦/២០២២ |
| ១១ | បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូលចំណាយ | ១លើក | ៧/២០១៩ | ៦/២០២២ |
| ១២ | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយដែននេសាទតំបន់អភិរក្ស | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយច្បាប់ជលផល / បរិស្ថាន / អនុក្រឹត.......... | ៣ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទនិងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |

ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោមៈ

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | ២០១៩ | ២០២១ | គណៈកម្មាការសហគមន៍នេសាទ | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅកម្មវិធីវិនិយោគឃុំ | ២០១៩ | ២០២១ | គណៈកម្មាការសហគមន៍នេសាទ | |

ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកភាពសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ៧/២០១៩ | ៦/២០២២ | | |
| ភាគទានប្រចាំឆ្នាំនិងភាគលាភពីក្រុមចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំពីសមាជិកចំនួន៦៥៣នាក់ ប៉ាន់ប្រមាណ៩៨នាក់ ប្រមូលបាន | ៧/២០១៩ | ៦/២០២២ | ៧៣,៥ | ៩៨នាក់ x ១.០០០ រៀល |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទមកពីខាងក្រៅប៉ាន់ប្រមាណចំនួន | ៧/២០១៩ | ៦/២០២២ | ១៦៨,៧៥ | ៤៥នាក់ x ១៥.០០០ |

| | | | | | |
|---|---|---|---|---|---|
| សហគមន៍នេសាទ ៦៤៧,២៥ | ១៥នាក់ ត្រូវបង់ប្រាក់ភាគទានចំនួន ១៥.០០០រៀល/រដូវនេសាទ | | | | រៀល |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ ប៉ាន់ប្រមាណចំនួន២៧០នាក់ ត្រូវបង់ប្រាក់ភាគទានចំនួន ២.០០០រៀល/រដូវនេសាទ | ៧/២០១៩ | ៦/២០២២ | ៤០៥ | ២៧០នាក់ x២.០០០ រៀល |
| • បដិភាគពីរាជរដ្ឋាភិបាល<br>• អំណោយពីសប្បុរសជន<br>• ជំនួយពីអង្គការជាតិ និងអង្គការមិនមែន<br>• រដ្ឋាភិបាល | • បញ្ចូលផែនការអភិវឌ្ឍន៍សហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយ<br>• ស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | ៩៥៩.២១៥ | |
| សរុប | | | | ៩៥៩.៨៦២,២៥ | |

ង. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំដោយមានការចូលរួមពីស្ត្រី និងជនជាតិភាគតិច | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់

- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមជិកសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាលសិក្ខាសាលា និងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រី ជាសមាជិកសហគមន៍នេសាទចូលរួមកិច្ចប្រជុំ និងចូលរួមសកម្មភាពនានារបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមសកម្មភាពគាំទ្រជីវភាព(ស្ត្រីជាមេគ្រួសារ ៧%)
- ផ្តល់ឱកាសដល់ស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទនៃអ្នកទទួលផលសរុបទទួលផលប្រយោជន៍ពីគម្រោង
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច ២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
